**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ព្រឹទ្ធសភា**
**អគ្គលេខាធិការដ្ឋាន**

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែមិថុនា និងទិសដៅការងារខែកក្កដា ឆ្នាំ២០១៤

*នៅក្នុងខែមិថុនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្ម លើការដ្ឋានជាច្រើន ដោយផ្សារភ្ជាប់បទដ្ឋានការងាររដ្ឋបាល បច្ចេកទេស នីតិវិធី និងហិរញ្ញវត្ថុ ជាពិសេសការរៀបចំប្រជុំគណៈកម្មការជំនាញ គណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គ លើកទី៤ ការបណ្តុះបណ្តាលធនធានមនុស្ស ការរៀបចំគម្រោងថវិកា ការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងសកម្មភាពការងារសង្គម និងខិតខំពង្រឹងពង្រីកភាពសុខដុមផ្ទៃក្នុង បង្កើនការសន្សំសំចៃខ្ពស់ បង្កើតសេវាថ្មីៗ កសាងគោលនយោបាយនានា បង្កើនកិច្ចសហប្រតិបត្តិការជាតិ អន្តរជាតិ និងបំពេញការងារសំខាន់ៗមួយចំនួនទៀតដូចខាងក្រោម៖*

## I.លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

*-បានចាត់ចែងរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ ចំនួន០២លើក ប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន០៣លើក ប្រជុំពិនិត្យ និងវាយតម្លៃលើការស្នើសុំគ្រឿងឥស្សរិយយសជូនមន្ត្រីរាជការសម្រាប់ឆ្នាំ២០១៣ ការវាយតម្លៃតាំងស៊ប់ក្នុងមុខតំណែងមន្ត្រីរាជការចំនួន១០៦រូប ប្រជុំស្តីពីការរៀបចំកសាងគម្រោងថវិកា ឆ្នាំ២០១៥ របស់ព្រឹទ្ធសភា ប្រជុំពិគ្រោះយោបល់ ស្តីពីក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពគ្រប់គ្រង(២០១៤-២០២៤) និងទស្សនវិស័យនៃដំណើរទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា(២០១៤-២០២៤) ប្រជុំផ្សព្វផ្សាយអំពីការងារចំពោះមុខ និងយូរអង្វែងរបស់ស្ថាប័ន ចូលរួមសិក្ខាសាលាប្រចាំឆ្នាំលើកទី២ ស្តីពីការគ្រប់គ្រងដោយបើកចំហ និងមានតម្លាភាព និងថវិកា នៅទីក្រុងOttawa ប្រទេសកាណាដា និងចូលរួមប្រជុំពិភាក្សាការងារផ្សេងៗ ព្រមទាំងបានពិនិត្យសម្រេចលើឯកសារផ្សេងៗចំនួន៤០៧ច្បាប់ ។*

### ១.សេវាទ្រទ្រង់មុខងារនីតិកម្ម៖

*-បានរៀបចំប្រជុំផ្ទៃក្នុងគណៈកម្មការជំនាញ និងប្រជុំអន្តរគណៈកម្មការព្រឹទ្ធសភាជាមួយនឹងតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០៨ ។*

**២.សេវាទទួលខុសត្រូវការតំណាង៖**

-បានរៀបចំវេទិកាតាមភូមិភាគទី៨ ស្តីពីគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងយេនឌ័រ នៅខេត្តស្ទឹងត្រែង ។

-ទទួលពាក្យបណ្តឹង ចំនួន០២ករណី និងបានទទួលលិខិតឆ្លើយតបការដោះស្រាយពាក្យបណ្តឹង ពីក្រសួងយុត្តិធម៌ ចំនួន០២ករណី ។

-រៀបចំបែបបទ និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ចុះទៅតាមបណ្តាខេត្ត រាជធានីទូទាំងប្រទេសចំនួន៤២លើក ដើម្បីសំណេះសំណាល ជួបពិភាក្សាការងារ សាកសួរសុខទុក្ខ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗសរុបចំនួន ១៦លើក ។

**៣.ការទំនាក់ទំនងអន្តរជាតិ៖**

-ទទួលជួបជាមួយអគ្គរដ្ឋទូតរុស្ស៊ី អគ្គរដ្ឋទូតកាណាដា ។

-វិទ្យាស្ថានសភាកម្ពុជាគាំទ្រលើវគ្គបណ្តុះបណ្តាលសម្រាប់ឆ្នាំ២០១៤ ចំនួន០៤វគ្គ ។

-រៀបចំបែបបទជូនគណៈប្រតិភូព្រឹទ្ធសភា ទៅចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍សេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចិរភាព ក្នុងក្របខ័ណ្ឌសភា អាស៊ី(APA) នៅប្រទេសឥណ្ឌូនេស៊ី កិច្ចប្រជុំ AIPA Caucus លើកទី៦ នៅប្រទេសប្រ៊ុយណេ កិច្ចប្រជុំវាំងអាយប៉ា និងថ្នាក់ដឹកនាំអាស៊ាន នៅប្រទេសមីយ៉ាន់ម៉ា កិច្ចប្រជុំ AIFOCOM លើកទី១១ នៅប្រទេសឡាវ កិច្ចប្រជុំ APAត្រីភាគីបូក នៅសាធារណរដ្ឋអ៊ីស្លាមប៉ាគីស្ថាន សិក្ខាសាលាអន្តរជាតិប្រចាំឆ្នាំលើកទី២ ស្តីពីរដ្ឋាភិបាលបើកចំហ តម្លាភាព ព័ត៌មាន និងថវិកា នៅប្រទេសកាណាដា និងកិច្ចប្រជុំAPA នៅរាជធានីភ្នំពេញ ។

-រៀបចំបែបបទជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន០៤រូប ទៅចូលរួមកិច្ចប្រជុំGlobal Service Outsourcing Summit 2014 នៅប្រទេសចិន និង០៤រូបទៀត ទៅបំពេញទស្សនកិច្ចសិក្សានៅប្រទេសសិង្ហបុរី ។

-ទំនាក់ទំនងជាមួយដៃគូអន្តរជាតិនានា (ឥណ្ឌា ប្រ៊ុយណេ ហ្វីលីពីន ឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាម ថៃ រុស្ស៊ី អាល្លឺម៉ង់ អូស្ត្រាលី ស្ថានកុងស៊ុលបែលហ្ស៊ិក ស្ថានកុងស៊ុលន័រវែស ) ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

**៤.ទំនាក់ទំនងសាធារណៈ**

-ទំនាក់ទំនងជាមួយស្ថានីយ៍ទូរទស្សន៍ជាតិទូរទស្សន៍អាស៊ីអាគ្នេយ៍ ដើម្បីផ្សព្វផ្សាយសមិទ្ធផលនានារបស់ព្រឹទ្ធសភា និងសាកលវិទ្យាល័យ CUS, CMTC, CDC, AEU, ECCC, CWF, NIDA, Hong kong Center សាកលវិទ្យាល័យមេគង្គកម្ពុជា សាកលវិទ្យាល័យន័រតុន និងចំរើនពហុបច្ចេកវិទ្យា ដើម្បីសុំអាហារូបករណ៍ និងទស្សនកិច្ចសិក្សា ។

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត សាធារណៈជន ចូលអានសៀវភៅ ចំនួន៤៤៨នាក់ និងសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រវិទ្យាសាស្ត្រសេដ្ឋកិច្ចចំនួន៤២នាក់ សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងតំណាងសហគមន៍មកពីខេត្តកំពង់ធំចំនួន៥០នាក់ និងអង្គការអ្នកស្ម័គ្រចិត្តបារាំងចំនួន១៦នាក់ មកទស្សនកិច្ចព្រឹទ្ធសភា ។

-នាំយកសៀវភៅដែលទាក់ទងនឹងកម្រងលិខិតបទដ្ឋានច្បាប់វិមជ្ឈការ វិសហមជ្ឈការរដ្ឋបាលទូទៅ ភាពជាអ្នកដឹកនាំ ទ្រឹស្តីគ្រប់គ្រង និងសៀវភៅផ្សេងៗទៀត ចំនួន២៨៨ក្បាល និងព្រឹត្តបត្រព័ត៌មានព្រឹទ្ធសភា ចំនួន១២០ក្បាល ជូនបណ្ណាល័យសាលាស្រុកខ្សាច់កណ្តាល ។

**៥.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-បើកវគ្គបណ្តុះបណ្តាលក្នុងប្រទេស ចំនួន១០វគ្គ ស្តីពីការគ្រប់គ្រងធនធានមនុស្សនៅក្នុងអាស៊ានវគ្គជំនាញក្នុងការធ្វើបទបង្ហាញ និងនិយាយជាសាធារណៈ វគ្គភាពជាដៃគូឯកជន និងសាធារណៈ វគ្គអ្នកគ្មានឯកទេសច្បាប់ វគ្គអ្នកដឹកនាំតាមបែបព្រះពុទ្ធសាសនា វគ្គគន្លឹះដើម្បីភាពជោគជ័យផ្ទាល់ខ្លួន វគ្គរចនាគេហទំព័រJoomla វគ្គថែទាំកុំព្យូទ័រ វគ្គភាសាជប៉ុន (ក្រុម១ ជំហ៊ាន៦ និងក្រុម២ ជំហ៊ាន៣) ។

-មន្ត្រីចំនួន០៤រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការស្តារនីតិសម្បទាអនីតិជន និង០២រូបទៀតចូលរួមវគ្គកំណែទម្រង់ស្ថាប័នរដ្ឋតាមរយៈយុទ្ធសាស្ត្រ Blue Ocean នៅប្រទេសម៉ាឡេស៊ី ។

-អាហារូបករណ៍ថ្នាក់បរិញ្ញាជាន់ខ្ពស់ នៅប្រទេសអាល្លឺម៉ង់ ចំនួន០១នាក់ និងថ្នាក់ភាសាចិនរយៈពេល១ឆ្នាំ នៅប្រទេសចិនចំនួន០២នាក់ ។

**៦.ការអភិវឌ្ឍស្ថាប័ន៖**

-រដ្ឋាភិបាលចិនយល់ព្រមសាងសង់អគារ១ខ្នងជូនព្រឹទ្ធសភា (ការប្តូរកំណត់ទូតជាផ្លូវការ) ។

-រដ្ឋសភាវៀតណាមកំពុងសិក្សាអំពីការបំពាក់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន នៅក្នុងព្រឹទ្ធសភាកម្ពុជា (ការសិក្សាបច្ចេកទេសជាមួយក្រុមហ៊ុនEZECOM ) ។

-ការរៀបចំជួសជុលឡើងវិញអតីតអគារសម្ព័ន្ធភាពជាតិឃុំ-សង្កាត់ ធ្វើជាមជ្ឈមណ្ឌលបច្ចេកវិទ្យាព័ត៌មាន និងការបន្តសំអាតម៉ាបនៅអគារចិនថ្មី៣ខ្នង ។

**៧. ការងារផ្ទៃក្នុង សន្តិសុខធនធាន មធ្យោបាយ ទីកន្លែង៖**

-បន្តប្រជុំពិនិត្យឯកសារ ស្តីពីសេចក្តីកំណត់ និងនីតិវិធីអនុវត្តចំពោះប្រការទាំងឡាយនៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នីតិកាលទី៣ ។

-វាយតម្លៃការអនុវត្តផែនការប្រតិបត្តិប្រចាំឆមាសទី១ ឆ្នាំ២០១៤ ។

-រៀបចំផ្តល់កាតATM ធនាគារអេស៊ីលីដា ជូនមន្ត្រី/សមាជិក ។

-ធ្វើរបាយការណ៍លទ្ធកម្ម និងការប្រើប្រាស់ថវិកាស្ថាប័នប្រចាំឆមាសទី១ ឆ្នាំ២០១៤ ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

-បានផ្សព្វផ្សាយសេចក្តីជូនដំណឹង ស្តីពីអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ សិក្សានៅប្រទេសអូស្ត្រាលី និងអាហារូបករណ៍រយៈពេលខ្លី នៅប្រទេសឥណ្ឌា ។

-ធ្វើបច្ចុប្បន្នភាពវគ្គបណ្តុះបណ្តាលឆ្នាំ២០១៤ ឆមាសទី១ ។

-ប្រជុំដោះស្រាយការប្រលងផ្ទេរក្របខ័ណ្ឌ តាមរយៈការត្រួតពិនិត្យ ពិនិត្យសញ្ញាបត្របញ្ជាក់ការសិក្សា និងទំនាក់ទំនងផ្ទាល់ជាមួយសាលា ។

-អង្គភាពសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា បានចាត់កងកម្លាំងការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗ ចំនួន១៦លើក ។

-ថតចម្លងឯកសារ ចំនួន១១៣សំណើ ចងក្រងឯកសារជាសៀវភៅ ចំនួន២៩ក្បាល ដោះស្រាយសំណើថវិកា ចំនួន៣២៤សំណើ និងសម្ភារចំនួន៦៩សំណើ ព្រមទាំងផ្តល់សេវាដឹកជញ្ជូនចំនួន៧៤លើក ។

-ទទួលសម្ភារខូច ទូទឹកកក ចំនួន០១គ្រឿង ប្រគល់កុំព្យូទ័រលើតុ ម៉ាស៊ីនហ្វូតូកូពី ចំនួន០៣គ្រឿង និងទឹកថ្នាំម៉ាស៊ីនហ្វូតូកូពី ចំនួន២៥ដប បំពាក់កង្ហារបឺត ចំនួន០២គ្រឿង និងបិទលេខកូដកៅអីវិលតុដែក និងទូរដាក់ឯកសារ ចំនួន១១គ្រឿង ។ បញ្ចូលហ្គាស ជួសជុល ម៉ាស៊ីនត្រជាក់ បន្ទប់ទឹក ទូរស័ព្ទ ប្តូរអំពូល ព្រី កុងតាក់ ឌីសង់ទ័រ អូតូទ្វារអាលុយមីញ៉ូម ទ្វារ សោទ្វារ សោថតតុ ចំនួន១០៦គ្រឿង ។

-ជួសជុលកុំព្យូទ័រ ត្រួតពិនិត្យ បញ្ចូលកម្មវិធីកំចាត់មេរោគ Update Files Antivirus បញ្ចូលកម្មវិធីខ្មែរ Unicode, Office ចុះតាមដាន Internet និង Network សរុបចំនួន២៩គ្រឿង និងបាន Upload ព័ត៌មាន និងឯកសារផ្សេងៗ ចំនួន៥២ ប្រធានបទ ។

## II.ទិសដៅការងារខែកក្កដា ឆ្នាំ២០១៤

### ១.សេវាទទួលខុសត្រូវការងារនីតិកម្ម៖

-ត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា (មានច្បាប់០៤ មកដល់ព្រឹទ្ធសភា ច្បាប់០៣ ចាត់ទុកជាការប្រញាប់) ។

**២.សេវាទ្រទ្រង់មុខងារត្រួតពិនិត្យ/ ព័ត៌មាន៖**

-ត្រៀមសម្រួលការជួបសវនាការរវាងគណៈកម្មការជំនាញ និងក្រសួងស្ថាប័ននានា និងការចុះបេសកកម្មតាមបណ្តាខេត្ត ។

**៣.សេវាទ្រទ្រង់មុខងារតំណាង៖**

-ការរៀបចំវេទិកាសាធារណៈរបស់ក្រុមសមាជិកព្រឹទ្ធសភា តាមភូមិភាគ រួមទាំងវេទិកាក្រុមសមាជិកាព្រឹទ្ធសភា ។

**៤.ការងារអន្តរជាតិ៖**

-ត្រៀមរៀបចំពិធីជំនួបរវាងថ្នាក់ដឹកនាំជាមួយគណៈប្រតិភូបរទេស និងអគ្គទូតនានា ។

-ត្រៀមរៀបចំបែបបទជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា បំពេញបេសកកម្មក្រៅប្រទេស រួមទាំងអគ្គលេខាធិការដ្ឋាន៖

-ទស្សនកិច្ចសិក្សានៅប្រទេសឥណ្ឌូណេស៊ី ម៉ាឡេស៊ី ថៃ (ខែកញ្ញា២០១៤)

-ទស្សនកិច្ចនៅប្រទេសចិន (គណៈកម្មការទី៩ និងអគ្គលេខាធិការដ្ឋាន)

-កិច្ចប្រជុំនៅOTTAWA ខែកក្កដា

-កិច្ចប្រជុំនៅប្រទេសសេរីលង្កា ។

-កិច្ចសហប្រតិបត្តិការជាមួយ KOICA, JICA, CAMSERV, វៀតណាម ឥណ្ឌា ឥណ្ឌូនេស៊ី សិង្ហបុរី ម៉ាឡេស៊ី កូរ៉េ ចិន ប្រ៊ុយណេ វិទ្យាស្ថានធនាគារពិភពលោក វិទ្យាស្ថានសភាកម្ពុជា និងដៃគូផ្សេងទៀត ។

-បន្តយុទ្ធនាការស្វែងរកការគាំទ្រ និងជំនួយពីប្រភពក្នុង/ក្រៅប្រទេស សំរាប់ព្រឹទ្ធសភាតាមរយៈវិទ្យាស្ថានសភាកម្ពុជា ។

**៥.ការអភិវឌ្ឍន៍ធនធានមនុស្ស៖**

-ត្រៀមរៀបចំបែបបទជូនមន្ត្រីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ទៅចូលរៀនវគ្គសិក្សាភាសាអង់គ្លេស នៅប្រទេសថៃ និងវគ្គរដ្ឋបាលសាធារណៈ នៅប្រទេសម៉ាឡេស៊ី ។

-ជំរុញលើកកម្ពស់ចំណេះដឹង ជំនាញភាសាបរទេស និងបច្ចេកវិទ្យាព័ត៌មាន និងយកចិត្តទុកដាក់ដល់ការពង្រឹងវិន័យ និងសណ្តាប់ធ្នាប់សាធារណៈ ។

**៦.ការងារផ្ទៃក្នុង សន្តិសុខ ធនធាន មធ្យោបាយ ទីកន្លែង៖**

-ត្រៀមចូលរួមពិធីគោរពព្រះវិញ្ញាណក្ខ័ន្ធ និងដង្ហែព្រះបរមអដ្ឋិ ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ ព្រះករុណា ព្រះបរមរតនកោដ្ឋ (១០,១១,១២ កក្កដា ២០១៤) ។

-រៀបចំគម្រោងថវិកាឆ្នាំ២០១៩ របស់ព្រឹទ្ធសភា (ជួងគណៈកម្មការទី២ គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។

-សិក្សាអំពីការដាក់ឲ្យអនុវត្តអង្គភាពថវិកា សម្រាប់០៤អង្គភាព ជាជំហានដំបូង ។

-បន្តពង្រឹងដំណើរការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងជំរុញការចាប់ផ្តើមដំណើរការរបស់អង្គភាពសវនកម្មផ្ទៃក្នុង ។

-គិតគូរអំពីការប្រលងផ្ទេរក្របខ័ណ្ឌ ការតាំងស៊ប់ក្នុងមុខតំណែង ការផ្តល់គ្រឿងឥស្សរិយយសដល់មន្ត្រីរាជការ ការបំពេញតម្រូវការរបស់នាយកដ្ឋានភូមិភាគ និងនាយកដ្ឋានហិរញ្ញ ។

-បង្កើនសមត្ថភាពស្រាវជ្រាវអំពីឯកសារ និងទិន្នន័យបច្ចុប្បន្នភាពរបស់ជាតិ ដើម្បីពង្រឹងសមត្ថភាពការងារ ។

**III.សេចក្តីសន្និដ្ឋាន**

ក្នុងខែមិថុនានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានរៀបចំប្រជុំគណៈកម្មការជំនាញ គណៈកម្មាធិការអចិន្ត្រៃយ៍ សម័យប្រជុំពេញអង្គលើកទី៩ ដើម្បីពិនិត្យ និងឲ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៣ ជាពិសេសការរៀបចំគម្រោងថវិកាព្រឹទ្ធសភា សម្រាប់ឆ្នាំ២០១៩ ។ អគ្គលេខាធិការដ្ឋានកំពុងបន្តសិក្សាលើក្របខ័ណ្ឌយុទ្ធសាស្ត្រ និងផែនការសកម្មភាពសម្រាប់ពង្រឹងសមត្ថភាពស្ថាប័ន (២០១៤-២០២៤) និងទស្សនវិស័យនៃដំណើរទៅមុខរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា(២០១៤-២០២៤)។ ការងារមូលដ្ឋានលេចធ្លោវេទិកាថ្នាក់ខេត្ត នៅខេត្តស្ទឹងត្រែង ។ ការងារអន្តរជាតិផ្តល់ទស្សនវិស័យថ្មីមានសម្រាប់ការពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា (ជំនួយចិន វៀតណាម កូរ៉េ កាណាដា ថៃ សិង្ហបុរី ។

ភ្នំពេញ,ថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៨

**អគ្គលេខាធិការ**

**អ៊ុំ.សារ៉ឹទ្ធ**